ជំពូកទី ៤

# របៀបថែទាំអ្នកជំងឺ

ការមានជំងឺធ្វើឲ្យរាងកាយចុះខ្សោយ។ ដើម្បីឲ្យមានកម្លាំងនិងស្រួលខ្លួនឡើងវិញយ៉ាងឆាប់រហ័ស គេត្រូវការការថែទាំជាចាំបាច់។

**ការថែទាំដែលអ្នកជំងឺម្នាក់បានទទួល គឺជាផ្នែកដ៏សំខាន់បំផុតនៃការព្យាបាលរបស់គាត់។**

ជាញឹកញាប់ ថ្នាំពេទ្យពុំមែនសុទ្ធតែចាំបាច់ទេ។ ប៉ុន្តែការថែទាំដ៏ល្អ តែងតែជាការសំខាន់។ អត្ថបទតទៅនេះ គឺជាមូលដ្ឋាននៃការថែទាំដ៏ល្អ ៖

## ១. ភាពសុខស្រួលរបស់អ្នកជំងឺ



អ្នកជំងឺគួរសម្រាកនៅកន្លែងដែលស្ងាត់ មានជាសុខភាព មានខ្យល់អាកាសល្អ និងមានពន្លឺគ្រប់គ្រាន់។ គាត់គួរសម្រាកនៅកន្លែងដែលមិនត្រជាក់ពេក ឬក្តៅពេក។ បើមានខ្យល់ត្រជាក់ ឬអ្នកជំងឺញាក់ ត្រូវដណ្តប់ភួយឬក្រណាត់ឲ្យគាត់។ ប៉ុន្តែ បើអាកាសធាតុក្តៅ ឬអ្នកជំងឺមានគ្រុនក្តៅ គាត់មិនត្រូវដណ្តប់អ្វីទាំងអស់(ទំ.៧៥)។



## ២. ទឹក

ស្ទើរតែគ្រប់ជំងឺទាំងអស់ ជាពិសេសក្នុងពេលមានគ្រុនក្តៅឬជំងឺរាក អ្នកជំងឺគួរផឹកទឹកឲ្យបានច្រើន ដូចជាទឹកស្អាត ទឹកតែ ទឹកផ្លែឈើ ទឹកស៊ុប។ល។

## ៣. អនាម័យផ្ទាល់ខ្លួន

ការរក្សាអនាម័យដល់អ្នកជំងឺគឺជាការសំខាន់ណាស់។ គាត់គួរងូតទឹកជារៀងរាល់ថ្ងៃ។ ប្រសិនបើគាត់ឈឺធ្ងន់ រហូតមិនអាចក្រោកបាន ត្រូវជូតខ្លួនគាត់ជាមួយក្រណាត់ និងទឹកក្តៅឧណ្ហៗ។ ខោអាវ ក្រណាត់ក្រាល និងភួយរបស់គាត់ ក៏ត្រូវតែស្អាតជានិច្ចដែរ។ មិនត្រូវមានកំទេច និងកាកសំណល់ចំណីអាហារនៅលើគ្រែទេ។




អ្នកជំងឺគួរងូតទឹករៀងរាល់ថ្ងៃ

## ៤. ចំណីអាហារដែលល្អ



ប្រសិនបើអ្នកជំងឺចង់បរិភោគចំណីអាហារអ្វីមួយ សូមអនុញ្ញាតឲ្យគាត់បរិភោគ។ ជំងឺភាគច្រើនមិនត្រូវការការតមអាហារទេ។

អ្នកជំងឺគួរផឹកទឹកឲ្យបានគ្រប់គ្រាន់ និងបរិភោគអាហារដែលមានជីវជាតិ(មើលជំពូកទី១១)។

បើអ្នកជំងឺអស់កម្លាំង ឲ្យគាត់បរិភោគអាហារដែលមានជីវជាតិឲ្យច្រើនតាមដែលគាត់អាចបរិភោគបាន ជាច្រើនដងក្នុងមួយថ្ងៃ។ បើចាំបាច់ កិនអាហារឲ្យម៉ត់ ឬធ្វើជាស៊ុប។

អាហារថាមពលមានសារសំខាន់យ៉ាងខ្លាំង ឧទាហរណ៍ បបរស្រូវសាលី ដំឡូង ឬត្រាវ។ ការបន្ថែមស្ករនិងប្រេងបន្ថែបន្តិច អាចជួយធ្វើឲ្យអាហារកាន់តែមានថាមពលថែមទៀត។ ម៉្យាងទៀត ត្រូវលើកទឹកចិត្តអ្នកជំងឺឲ្យផឹកទឹកដែលមានជាតិផ្អែមឲ្យបានច្រើន ជាពិសេសនៅពេលដែលគាត់បរិភោគអាហារមិនបានច្រើន។

មានជំងឺមួយចំនួនតូចត្រូវការការតមអាហារ។ ជំងឺទាំងនេះត្រូវបានពន្យល់តាមទំព័រនីមួយៗដូចតទៅ ៖


ជំងឺជំបៅក្រពះ និងឆ្អល់ពោះ.................................................. ទំ.១២៨

ជំងឺរលាកខ្នែងពោះវៀន ស្ទះពោះវៀន និងបញ្ហាពោះស្រួចស្រាល់
(ក្នុងករណីនេះ មិនត្រូវបរិភោគអាហារអ្វីទាំងអស់)...................... ទំ.៩៣

ជំងឺទឹកនោមផ្អែម.................................................................... ទំ.១២៧

ជំងឺបេះដូង..............................................................................ទំ.៣២៥

ជំងឺថង់ទឹកប្រមាត់....................................................................ទំ.៣២៩




## ការថែទាំពិសេសចំពោះអ្នកឈឺធ្ងន់

### ១. ទឹក

វាជាការសំខាន់ណាស់ដែលអ្នកជំងឺត្រូវផឹកទឹកឲ្យបានគ្រប់គ្រាន់។ ប្រសិនបើគាត់អាចផឹកបានតែបន្តិចបន្តួច នោះសូមឲ្យគាត់ផឹកឲ្យបានញឹកញាប់ ម្តងបន្តិចៗ។ ប្រសិនបើគាត់ពិបាកលេប ឲ្យគាត់ក្រេបទឹកបន្តិចៗ រាល់ប្រាំ ឬដប់នាទីម្តង។

ប៉ាន់ស្មានបរិមាណទឹកដែលអ្នកជំងឺផឹកក្នុងថ្ងៃៗ។ មនុស្សពេញវ័យម្នាក់ត្រូវការផឹកទឹកពីរលីត ឬច្រើនជាងនេះក្នុងមួយថ្ងៃ ហើយគួរតែបត់ជើងតូចយ៉ាងតិចមួយកែវ(ប្រហែល២០០មល) ៣ឬ៤ដងរៀងរាល់ថ្ងៃ។ បើអ្នកជំងឺផឹកទឹកឬបត់ជើងតូចមិនបានគ្រប់គ្រាន់ទេ ឬបើគាត់មានរោគសញ្ញានៃការខ្សោះជាតិទឹក(ទំ.១៥១) លើកទឹកចិត្តគាត់ឲ្យផឹកទឹកឲ្យបានច្រើនថែមទៀត។ គាត់គួរផឹកទឹកដែលមានជីវជាតិ ដែលជាធម្មតាត្រូវបន្ថែមអំបិលបន្តិច។ បើគាត់មិនចង់ផឹកនោះទេ គួរឲ្យគាត់ផឹកទឹកអូរ៉ាលីត(ទំ.១៥២)។ បើគាត់មិនអាចផឹកទឹកអូរ៉ាលីតនេះឲ្យបានគ្រប់គ្រាន់ ហើយមានរោគសញ្ញានៃការខ្សោះជាតិទឹកទៀត នោះបុគ្គលិកសុខាភិបាលប្រហែលជាអាចព្យួរសេរ៉ូមឲ្យគាត់។ ប៉ុន្តែតម្រូវការនៃការព្យួរសេរ៉ូមនេះ អាចជៀសវាងបាន ប្រសិនបើអ្នកជំងឺនៅតែអាចក្រេបទឹកបានបន្តិចៗ ជាញឹកញាប់។

## ២. ចំណីអាហារ

បើអ្នកដែលមានជំងឺធ្ងន់ មិនអាចបរិភោគអាហាររឹងបាន ឲ្យគាត់បរិភោគស៊ុប ទឹកដោះគោ ទឹកផ្លែឈើ បបរ និងអាហាររាវផ្សេងៗដែលមានជីវជាតិ(អានជំពូក១១)។ បបរ ក៏ជាអាហារល្អម្យ៉ាងដែរ ប៉ុន្តែគួរឲ្យបរិភោគជាមួយអាហារស្ថាបនារាងកាយផងដែរ។ ស៊ុបអាចធ្វើដោយមានលាយជាមួយស៊ុត សណ្តែក សាច់ចិញ្ច្រាំ ត្រី ឬសាច់មាន់។ បើអ្នកជំងឺបរិភោគបានតិចៗ គួរឲ្យគាត់បរិភោគឲ្យបានច្រើនដង ម្តងបន្តិចៗ ជារៀងរាល់ថ្ងៃ។

## ៣. អនាម័យ

អនាម័យផ្ទាល់ខ្លួនមានសារសំខាន់ណាស់សំរាប់អ្នកជំងឺធ្ងន់។ គាត់គួរងូតទឹកក្តៅឧណ្ហៗរៀងរាល់ថ្ងៃ។

ប្តូរកម្រាលគ្រែជារៀងរាល់ថ្ងៃ និងរាល់ពេលដែលវាមានប្រឡាក់។ សំលៀកបំពាក់ដែលប្រឡាក់ ឬដែលប្រឡាក់ឈាម ពូក និងកន្សែងរបស់អ្នកដែលមានជំងឺឆ្លង គួរត្រូវបានរៀបចំដោយប្រុងប្រយ័ត្ន។ ដើម្បីសម្លាប់វីរុសឬមេរោគផ្សេងៗ ត្រូវលាងសម្ភារៈទាំងនេះដោយប្រើទឹកក្តៅលាយសាប៊ូ ឬមានបន្ថែមទឹកលាងសម្អាតដែលមានក្លរ។

## ៤. ការផ្លាស់ប្តូរស្ថានភាពរបស់អ្នកជំងឺនៅលើគ្រែ

អ្នកជំងឺដែលខ្សោយខ្លាំង ហើយមិនអាចប្រែខ្លួនដោយខ្លួនឯងបាន គួរត្រូវបានជួយឲ្យប្រែខ្លួននៅលើគ្រែឲ្យបានច្រើនដងរៀងរាល់ថ្ងៃ។ ការធ្វើរបៀបនេះនឹងជួយការពារកុំឲ្យកើតដំបៅម្យ៉ាង ហៅថាដំបៅគ្រែ(ទំ.២១៤)។

កុមារដែលមានជំងឺរយៈពេលយូរ គួរឲ្យម្តាយលើកមកបីឲ្យបានញឹកញាប់។

ការផ្លាស់ប្តូរស្ថានភាពរបស់អ្នកជំងឺឲ្យបានញឹកញាប់ ក៏អាចជួយបង្ការជំងឺរលាកសួតផងដែរ ដែលជាជំងឺដ៏គ្រោះថ្នាក់មួយ សំរាប់អ្នកដែលខ្សោយ ឬឈឺធ្ងន់ ហើយត្រូវសម្រាកលើគ្រែជាប់ក្នុងរយៈពេលយូរ។ ប្រសិនបើអ្នកជំងឺមានគ្រុនក្តៅហើយ ចាប់ផ្តើមមានក្អក និងដកដង្ហើមញាប់ៗ ខ្លីៗ នោះគាត់ប្រហែលជាមានជំងឺរលាកសួត(ទំ.១៧១)។

## ៥. ការពិនិត្យមើលការប្រែប្រួលរបស់អ្នកជំងឺ

អ្នកគួរពិនិត្យមើលរាល់ការប្រែប្រួលនៃសភាពរបស់អ្នកជំងឺ។ ការធ្វើនេះអាចប្រាប់អ្នកថាតើគាត់មានការធូរស្រាល ឬកាន់តែធ្ងន់ធ្ងរ។ ត្រូវរក្សាទុកឲ្យបានល្អនូវការកត់ត្រាអំពី "សញ្ញាជីវិត" របស់អ្នកជំងឺ។ កត់ត្រាចំណុចខាងក្រោមនេះក្នុងមួយថ្ងៃបួនដង ៖



*សីតុណ្ហភាព*
*(មានប៉ុន្មានអង្សា)*



*ជីពចរ*
*(ប៉ុន្មានដងក្នុងមួយនាទី)*



*ចង្វាក់ដង្ហើម*
*(ចង្វាក់ក្នុងមួយនាទី)*

ចូរកត់ត្រាផងដែរនូវបរិមាណទឹកដែលអ្នកជំងឺបានផឹក និងចំនួនដងដែលអ្នកជំងឺបត់ជើងតូច និងបត់ជើងធំ ក្នុងមួយថ្ងៃៗ។ រក្សាព័ត៌មានទាំងនេះទុកឲ្យបុគ្គលិកសុខាភិបាល ឬវេជ្ជបណ្ឌិត។

វាជាការសំខាន់ណាស់ដែលត្រូវពិនិត្យមើលរោគសញ្ញាដែលព្រមានថាសភាពរបស់អ្នកជំងឺកំពុងតែធ្ងន់ធ្ងរ ឬមានគ្រោះថ្នាក់។ នៅទំព័របន្ទាប់នេះមានបញ្ជីដែលរាយ**រោគសញ្ញានៃជំងឺដែលមានគ្រោះថ្នាក់។** ប្រសិនបើអ្នកជំងឺមានរោគសញ្ញាណាមួយក្នុងចំណោមរោគសញ្ញាទាំងនេះ **ត្រូវរកជំនួយពីគ្រូពេទ្យជាបន្ទាន់។**

# រោគសញ្ញានៃជំងឺដែលមានគ្រោះថ្នាក់



អ្នកដែលមានរោគសញ្ញាមួយឬច្រើន ក្នុងចំណោមរោគសញ្ញាខាងក្រោមនេះ ប្រហែលជាមានជំងឺធ្ងន់ធ្ងរដែលមិនអាចធ្វើការព្យាបាលនៅផ្ទះ ដោយគ្មានជំនួយពីគ្រូពេទ្យជំនាញបានទេ។ ជីវិតរបស់គាត់អាចស្ថិតក្នុងគ្រោះថ្នាក់។ **ត្រូវរកជំនួយពីគ្រូពេទ្យឲ្យបានលឿនបំផុត។** នៅពេលដែលជំនួយមិនទាន់មកដល់ ធ្វើតាមសេចក្ដីណែនាំនៅក្នុងទំព័រដែលបានបង្ហាញនេះ។

**ទំព័រ**


១. ការបាត់បង់ឈាមយ៉ាងច្រើន ចេញមកពីកន្លែងណាមួយនៃរាងកាយ..........................ទំ.៨២, ២៦៤, ២៨១

២. ការក្អកធ្លាក់ឈាម.......................................................................................... ទំ.១៧៩

៣. បបូរមាត់និងក្រចកឡើងពណ៌ស្វាយ(បើទើបមានថ្មីៗ)........................................................ ទំ.៣០

៤. ការពិបាកដកដង្ហើមយ៉ាងខ្លាំង ហើយគ្មានការធូរស្រាលដោយការសម្រាក..........................ទំ.១៦៧, ៣២៥

៥. មនុស្សដែលមិនអាចដាស់ឲ្យភ្ញាក់បាន(សន្លប់)........................................................ ទំ.៧៨

៦. មនុស្សដែលខ្សោយខ្លាំង ដួលនៅពេលដែលគាត់ក្រោកឈរ.....................................................ទំ.៣២៥

៧. មិនអាចបត់ជើងតូចបានរយៈពេលមួយថ្ងៃឬច្រើនជាងនេះ ...................................................ទំ.២៣៤

៨. មិនអាចផឹកទឹកបានរយៈពេលមួយថ្ងៃឬច្រើនជាងនេះ.................................................... ទំ.១៥១

៩. ក្អួតឬរាកយ៉ាងធ្ងន់ធ្ងរ រយៈពេលលើសពីមួយថ្ងៃ ឬលើសពីពីរបីម៉ោង ចំពោះទារក............................ទំ.១៥១

១០. មានលាមកពណ៌ខ្មៅដូចកៅស៊ូថ្នល់ ឬក្អួតមានឈាមឬលាមក...................................................ទំ.១២៨

១១. ឈឺពោះខ្លាំងជាប់រហូត និងក្អួតផង ចំពោះមនុស្សដែលគ្មានរាក ឬដែលគ្មានបត់ជើងធំ.......................ទំ.៩៣

១២. មានការឈឺចាប់ខ្លាំង ជាប់លើសពីបីថ្ងៃ......................................................... ទំ.២៩ ទៅ ៣៨

១៣. មានរឹងក និងកោងខ្នង ដោយមានឬគ្មានរឹងថ្គាម ................................................ ទំ.១៨២, ១៨៥

១៤. ប្រកាច់លើសពីម្ដង ចំពោះអ្នកដែលមានគ្រុនក្ដៅឬជំងឺធ្ងន់ធ្ងរ................................................ ទំ.៧៦, ១៨៥

១៥. គ្រុនក្ដៅខ្លាំង(លើស៣៩អង្សាសេ) ដែលមិនអាចបញ្ចុះបាន ឬលើសពី៤ឬ៥ថ្ងៃ..................................ទំ.៧៥

១៦. ស្រកទម្ងន់ក្នុងអំឡុងពេលយូរ......................................................................... ទំ.២០០, ៤០០

១៧. មានឈាមនៅក្នុងទឹកនោម.................................................................................ទំ.១៤៦, ២៣៤

១៨. ដំបៅដែលចេះតែរីកធំឡើងៗ ហើយព្យាបាលមិនជាសះ.......................... ទំ.១៩១, ១៩៦, ២១១, ២១២

១៩. មានដុំពកនៅកន្លែងណាមួយនៃរាងកាយ ដែលចេះតែរីកធំឡើងៗ.................................... ទំ.១៩៦, ២៨០

២០. មានបញ្ហាដែលទាក់ទងនឹងការមានផ្ទៃពោះ និងការសម្រាលកូន ៖

ធ្លាក់ឈាមក្នុងពេលមានផ្ទៃពោះ.................................................................................ទំ.២៤៩, ២៨១

ហើមមុខ និងស្រវាំងភ្នែក ក្នុងអំឡុងខែចុងក្រោយ.........................................................ទំ.២៤៩

ការបន្លាយពេលយូរបន្ទាប់ពីបែកទឹកភ្លោះ ហើយការឈឺពោះសម្រាលបានចាប់ផ្ដើម.........................ទំ.២៦៧

ធ្លាក់ឈាមយ៉ាងខ្លាំង.................................................................................................ទំ.២៦៤

## ត្រូវរកជំនួយពីគ្រូពេទ្យនៅពេលណា និងដោយរបៀបណា

ត្រូវរកជំនួយពីគ្រូពេទ្យនៅពេលមានរោគសញ្ញាដំបូងនៃជំងឺដែលមានគ្រោះថ្នាក់។ មិនត្រូវរង់ចាំរហូតដល់អ្នកជំងឺមានសភាពធ្ងន់ធ្ងរពេក ដែលអាចធ្វើឲ្យពិបាកឬមិនអាចយកគាត់ទៅមណ្ឌលសុខភាពឬមន្ទីរពេទ្យបាននោះទេ។

ប្រសិនបើសភាពរបស់អ្នកជំងឺឬអ្នកមានរបួស អាចក្លាយទៅជាកាន់តែធ្ងន់ធ្ងរដោយសារការពិបាកក្នុងការនាំគាត់ទៅមណ្ឌលសុខភាព ព្យាយាមអញ្ជើញបុគ្គលិកសុខាភិបាលមកពិនិត្យគាត់វិញ។ ប៉ុន្តែក្នុងករណីបន្ទាន់ ដែលត្រូវការការព្យាបាលពិសេស ឬត្រូវការការវះកាត់ (ឧទាហរណ៍ ជំងឺរលាកខ្នែងពោះវៀន) មិនត្រូវរង់ចាំបុគ្គលិកសុខាភិបាលទេ។ នាំអ្នកជំងឺទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យភ្លាម។

ប្រសិនបើអ្នកត្រូវសែងអ្នកជំងឺដោយស្នែង ត្រូវប្រាកដថាគាត់អាចដេកយ៉ាងស្រួលលើស្នែង និងមិនអាចធ្លាក់ចេញពីស្នែងបានទេ។ បើគាត់មានបាក់ឆ្អឹងណាមួយ អ្នកត្រូវអបឆ្អឹងនោះសិន មុននឹងធ្វើចលនាទៅលើគាត់(ទំ.៩៩)។ បើមានពន្លឺព្រះ អាទិត្យក្ដៅខ្លាំងពេក យកក្រណាត់មកចងបាំងពីលើស្នែង ដើម្បីឲ្យមានម្លប់ ប៉ុន្តែត្រូវទុកឲ្យខ្យល់ ចេញចូលបានល្អផង។



## ត្រូវប្រាប់បុគ្គលិកសុខាភិបាលអំពីអ្វីខ្លះ

ដើម្បីឲ្យបុគ្គលិកសុខាភិបាលឬវេជ្ជបណ្ឌិតអាចណែនាំអំពីការព្យាបាល ឬចេញវេជ្ជបញ្ជាឲ្យមានប្រសិទ្ធភាពនោះ គាត់គួរជួបជាមួយអ្នកជំងឺផ្ទាល់។ បើអ្នកជំងឺមិនអាចធ្វើដំណើរបាន អញ្ជើញគ្រូពេទ្យមកពិនិត្យគាត់វិញ។ បើមិនអាចទេ បញ្ជូនអ្នកទទួលខុសត្រូវម្នាក់ដែលដឹងច្បាស់អំពីសភាពជំងឺនេះ។ **មិនត្រូវឲ្យកុមារតូចៗ ឬមនុស្សមិនដឹងអ្វីសោះទៅទេ។**

មុននឹងបញ្ជូននរណាម្នាក់ទៅរកជំនួយពីគ្រូពេទ្យ ពិនិត្យអ្នកជំងឺឲ្យបានហ្មត់ចត់និងទាំងស្រុងជាមុនសិន។ បន្ទាប់មកកត់ត្រានូវព័ត៌មានលម្អិតអំពីជំងឺ និងសភាពទូទៅរបស់អ្នកជំងឺ(មើលជំពូក ៣)។

នៅទំព័របន្ទាប់នេះគឺជាទម្រង់បែបបទមួយដែលអ្នកអាចធ្វើ**របាយការណ៍របស់អ្នកជំងឺ** បាន។ នៅខាងចុងនៃសៀវភៅនេះ ក៏មានទម្រង់របាយការណ៍របស់អ្នកជំងឺនេះជាច្រើនច្បាប់ទៀត ។ សូមហែកវាមួយសន្លឹកចេញ ហើយបំពេញវាដោយប្រុងប្រយ័ត្ន ដោយផ្ដល់ព័ត៌មានលម្អិត តាមដែលអាចធ្វើបាន។

**នៅពេលដែលអ្នកបញ្ជូននរណាម្នាក់ទៅរកជំនួយពីគ្រូពេទ្យ ត្រូវបញ្ជូនទម្រង់របាយការណ៍របស់អ្នកជំងឺ ដែលបានបំពេញត្រឹមត្រូវ ទៅជាមួយអ្នកនោះផង។**

# របាយការណ៍របស់អ្នកជំងឺ

## សំរាប់ប្រើនៅពេលបញ្ជូននរណាម្នាក់ទៅរកជំនួយពីគ្រូពេទ្យ

ឈ្មោះអ្នកជំងឺ.................................................................................................. អាយុ..............................

ប្រុស...........ស្រី.............គាត់នៅឯណា?.......................................................................................

តើគាត់មានជំងឺ ឬបញ្ហាចម្បងអ្វី ក្នុងពេលនេះ?.........................................................................

.........................................................................................................................................

.........................................................................................................................................

តើជំងឺនេះចាប់ផ្ដើមនៅពេលណា?....................................................................................

តើជំងឺនេះចាប់ផ្ដើមយ៉ាងដូចម្ដេច?.................................................................................

តើអ្នកជំងឺធ្លាប់មានបញ្ហាដូចគ្នានេះពីមុនទេ?.................. នៅពេលណា?.................................................

តើមានគ្រុនក្ដៅឬទេ?...........ប៉ុន្មានអង្សាសេ?............តាំងពីពេលណា និងមានរយៈពេលប៉ុន្មាន?..................

មានការឈឺចាប់ទេ?.........ត្រង់កន្លែងណា?........................ឈឺយ៉ាងដូចម្ដុច?..........................................

**តើមានអ្វីកើតឡើង ឬខុសប្រក្រតី ចំពោះចំណុចខាងក្រោមនេះ?**

**ស្បែក** :.........................................................**ត្រចៀក** :..............................................................

**ភ្នែក** :.............................................................**មាត់និងបំពង់ក** :..................................................

**ប្រដាប់បន្តពូជ**:.................................................................................................................

**ទឹកនោម** : តិចឬក៏ច្រើន?.................ពណ៌អ្វី?.......................តើមានការពិបាកក្នុងការនោមឬទេ?................

ចូរពណ៌នា :..................................ប៉ុន្មានដងក្នុង២៤ម៉ោង?................ប៉ុន្មានដងក្នុងមួយយប់?.................

**លាមក** : ពណ៌អ្វី?.........................មានឈាមឬសំបោរ?......................មានរាគឬទេ?..............................

មួយថ្ងៃប៉ុន្មានដង?..................មានចុកពោះឬទេ?.....................មានការខ្សោះជាតិទឹកឬទេ?........................

ធ្ងន់ឬក៏ស្រាល?................មានព្រូនឬទេ?...............ព្រូនប្រភេទណា?...............................................

**ដង្ហើម** : ចង្វាក់ក្នុងមួយនាទី....................................វែង ខ្លី ឬធម្មតា?..............................................

ពិបាកដកដង្ហើម(ពណ៌នា)...............................................ក្អក(ពណ៌នា)...............................................

មានសំឡេងង៉ឺតៗដូចឆ្មា?......................មានស្លេសទេ?......................មានឈាមទេ?..............................

**តើអ្នកជំងឺមានរោគសញ្ញាណាមួយនៃជំងឺគ្រោះថ្នាក់**ដែលលើកឡើងនៅទំ.៤២ដែរឬទេ?..................................

រោគសញ្ញាមួយណា?(ពន្យល់លម្អិត) ..........................................................................................

.........................................................................................................................................

**រោគសញ្ញាផ្សេងទៀត** :.......................................................................................................

តើអ្នកជំងឺមានពិសារថ្នាំទេ?............................ថ្នាំអ្វី?..............................................................

តើអ្នកជំងឺធ្លាប់ប្រើថ្នាំដែលបណ្ដាលឲ្យកើតកន្ទាលត្រអាក(ឬដុំពក) រមាស់ ឬប្រតិកម្មទំនាស់អ្វីផ្សេងទៀត

ដែរទេ?..................................តើជាថ្នាំអ្វី?...........................................................................

សភាពរបស់អ្នកជំងឺ : មិនសូវធ្ងន់ធ្ងរ.........................ធ្ងន់ធ្ងរ...........................ធ្ងន់ណាស់.......................

នៅខាងក្រោយទម្រង់បែបបទនេះ ចូរសរសេរនូវព័ត៌មានផ្សេងៗទៀតដែលអ្នកយល់ថាមានសារសំខាន់។